00799086

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 10 / 04 / 2012
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/51

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ អង្គារ ទី ២០ ខែ មីនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៣៩

**រៀបចំដោយ: ដាវ អានសាន និង Roger PHILLIPS**

---

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក Roger PHILLIPS, លោកស្រី សែ កុលវុឌ្ឍី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង (សហព្រះរាជអាជ្ញារងជាតិ), លោក William SMITH (សហព្រះរាជអាជ្ញារងអន្តរជាតិ), លោក Golriz GHAHRAMAN, លោក ពេជ្រ សម្បត្តិ, លោក តូច វណ្ណារិទ្ធ, លោក ប៊ូ ចាន់ថន, លោក ប៉ាក់ ចាន់លីណូ។ |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ (សហមេធាវីជាតិ), លោក Michiel PESTMAN (សហមេធាវីអន្តរជាតិ), លោក Jasper PAUW, លោក ព្រំ ផល្លា។ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម (សហមេធាវីជាតិ), លោក Michael KARNAVAS (សហមេធាវីអន្តរជាតិ), លោក សូ មូស្សេទី, កញ្ញា Tanya PETTAY។ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន (សហមេធាវីជាតិ), និងលោកស្រី Anta GUISSE (សហមេធាវីអន្តរជាតិ), Ms. Marie CAPOTORTO។ |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ (សហមេធាវីនាំមុខជាតិ), លោកស្រី Elisabeth SIMONNEAU-FORT (សហមេធាវីនាំមុខអន្តរជាតិ), លោក ឡោ ជុនធី, លោកស្រី ម៉ុច សុវណ្ណារី, លោក ហុង គឹមសួន, លោក វ៉ែន ពៅ, លោកស្រី ទី ស្រ៊ីនណា, លោក Barnabé NEKUIE, លោកស្រី Lyma NGUYEN, លោកស្រី ស៊ិន សូវន។ |
| សាក្សី៖ កាំង ហ្កេចអ៊ាវ ហៅ ឌុច (TCW-281) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោក មៀច សុវណ្ណា, លោក Laurent SOULARD, លោកស្រី Nathalie TURCOVICH។ |
| ផ្សេងៗ៖ កញ្ញា Almaz TEFFERA |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃ អង្គារ ទី ២០ ខែ មីនា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៥.២០ (៦ម៉ោង១៥នាទី) |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ (២០នាទី) |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.00 | បញ្ចប់ម៉ោង៖ ១៣.៣៥ (១ម៉ោង៣៥នាទី) |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.00 (២០នាទី) |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ | | ៤ ម៉ោង |

| **<u>កិច្ចដំណើរការនីតិវិធី៖</u>** | | | |
|---|---|---|---|
| **ប្រភេទបញ្ហា** | **លើកឡើងដោយ** | **ម៉ោងចាប់ផ្តើម** | **ម៉ោងបញ្ចប់** |
| បង្គាប់សាក្សីឱ្យចូលក្នុងបន្ទប់សវនាការ | ប្រធានអង្គជំនុំជម្រះ | ៩.០៥ | ៩.០៥ |

| | | | |
|---|---|---|---|
| សាក្សីស្នើអង្គជំនុំជម្រះ ដើម្បីអាចសម្រួលឥរិយាបថអង្គុយ ក្នុងការឆ្លើយ | សាក្សី កាំង ហ្គេចអ៊ាវ | ៩.០៥ | ០៩.១០ |
| ការបន្តសួរសាក្សី កាំង ហ្គេចអ៊ាវ | តំណាងសហព្រះរាជអាជ្ញាជាតិ | ៩.១០<br>១៣.៣៥ | ១២.០០<br>១៥.២០ |
| ការលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវី អៀង សារី | ១០.៣០ | ១០.៣០ |
| កំណត់វិសាលភាពក្នុងការសួរសាក្សី កាំង ហ្គេកអ៊ាវ | អ.ជ.ស.ដ | ១០.៥០ | ១០.៥៥ |
| ការជំទាស់លើសក្ខីកម្មរបស់សាក្សី កាំង ហ្គេកអ៊ាវ | មេធាវី អៀង សារី និង នួន ជា | ១១.២០ | ១១.៥០ |
| ការជំទាស់នឹងរបៀបសួរសាក្សីរបស់សហព្រះរាជអាជ្ញា | មេធាវី អៀង សារី | ១៤.១៥ | ១៤.២០ |
| សំណើលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | នួន ជា | ១៥.០០ | ១៥.០០ |
| សំណើសុំពន្យាពេលសវនាការ | មេធាវី នួន ជា | ១៥.០៥ | ១៥.១០ |
| ការពិនិត្យស្ថានភាពសុខភាពនួន ជា | អង្គជំនុំជម្រះសាលាដំបូង | ១៥.១០ | ១៥.២០ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ និង ឲ្យនាំសាក្សីចូលក្នុងបន្ទប់សវនាការ។

**<u>សាក្សីស្នើអង្គជំនុំជម្រះ ដើម្បីអាចសម្រួលឥរិយាបថអង្គុយ ក្នុងការឆ្លើយ</u>**

សាក្សី កាំង ហ្គេចអ៊ាវ ស្នើសុំប្រធានអង្គជំនុំជម្រះ ដើម្បីខ្លួនអាចសម្រួលឥរិយាបថអង្គុយដោយផ្អែកទៅក្រោយ ដើម្បីនិយាយថា ធ្វើដូចនេះអាចឆ្លើយសំណួរបានយឺតៗ និងដកដង្ហើមបានស្រួល ក្នុងរយៈពេលយូរ។ ប្រធានអង្គជំនុំជម្រះអនុញ្ញាតតាមសំណើ។

**<u>ការបន្តសួរសាក្សី កាំង ហ្គេកអ៊ាវ</u>**

តំណាងសហព្រះរាជអាជ្ញាជាតិបន្តសួរសាក្សី កាំង ហ្គេកអ៊ាវ អំពីព្រឹត្តិការណ៍នានានៅមុនឆ្នាំ ១៩៧៥

(ចាប់ពីមន្ទីរ ម១៣), តួនាទីរបស់សាក្សីនៅមន្ទីរ ស-២១ និងមុខងារ ភារកិច្ចរបស់មន្ទីរនេះ, សកម្មភាពរបស់ឌុច ក្រោយឆ្នាំ ១៩៧៩, មនោគមវិជ្ជាបក្សកុម្មុយនីស្តកម្ពុជា។

**ការកំណត់វិសាលភាពក្នុងការសួរសាក្សី កាំង ហ្គេកអ៊ាវ**

អង្គជំនុំជម្រះរំលឹកដល់ភាគីឱ្យរៀបចំការសួររបស់ខ្លួនចំពោះសាក្សី តែទៅលើបញ្ហាពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងនេះ (០០២/០១)។ សហព្រះរាជអាជ្ញាជាតិផ្តល់ការបញ្ជាក់ពីវិសាលភាព និងប្តង់នៃសំណួររបស់ខ្លួន។

**ការជំទាស់លើសក្ខីកម្មរបស់សាក្សី កាំង ហ្គេកអ៊ាវ**

ក្រុមមេធាវី អៀង សារី និង នួន ជា ជំទាស់នឹងការផ្តល់សក្ខីកម្មរបស់សាក្សី កាំង ហ្គេកអ៊ាវ ដោយអះអាងថា សាក្សីលើកឡើងអំពីការវិភាគ ការសន្និដ្ឋាន លើអង្គហេតុមួយចំនួន ដែលសាក្សីមិនធ្លាប់បានជួបផ្ទាល់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែដោយសារការមើលឯកសារផ្សេងៗនៅក្រោយឆ្នាំ ១៩៧៩។ ប្រធានអង្គជំនុំជម្រះបង្គាប់សាក្សីឱ្យផ្តល់សក្ខីកម្មតែទៅតាមសំណួរ និងមិនត្រូវធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯង។

**ការជំទាស់នឹងរបៀបសួរសាក្សី របស់សហព្រះរាជអាជ្ញា**

មេធាវី អៀង សារី ជំទាស់នឹងវិធីសាស្ត្រសួរសាក្សី របស់សហព្រះរាជអាជ្ញា ដោយលើកឡើងពីការផ្តល់សំណួរដែលមានលក្ខណៈនាំមុខ ឬផ្តល់ពត៌មានជាមុន។

**ការលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

មេធាវីការពារក្តី អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ ប៉ុន្តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំ។ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើមេធាវីការពារក្តី អៀង សារី (ម៉ោង ១០.៣០ នាទី) ដោយបង្គាប់ឱ្យមេធាវីការពារក្តីប្រគល់លិខិតលះបង់សិទ្ធិជាលាយលក្ខណ៍អក្សរជូនអង្គជំនុំជម្រះ។ ក្រុមការពារក្តី អៀង សារី បានផ្តល់លិខិតលះបង់សិទ្ធិដល់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង។

**សំណើសុំលះបង់សិទ្ធក្នុងការចូលរួមសវនាការ និងសុំពន្យាពេលសវនាការ**

ជនជាប់ចោទ នួន ជា ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ ប៉ុន្តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំ ចំណែក មេធាវី នួន ជា ស្នើសុំពន្យាពេលសវនាការតែម្តង។ អង្គជំនុំជម្រះបង្គាប់ឱ្យវេជ្ជបណ្ឌិតពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដើម្បីវាយតម្លៃពីស្ថានភាពសុខភាពសម្រាប់ការចូលរួមសវនាការនៅវេលានេះ ប៉ុន្តែប្រកាសអសុពលភាពនៃការពិនិត្យនេះវិញ ដោយមេធាវី Michiel PESTMAN ចាកចេញពីបន្ទប់សវនាការ និងទៅចូលរួមមើលការពិនិត្យសុខភាពនេះដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣)</u>**

| TC No | OCIJ No | ចំណងជើង | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|
| E3/147 | D262.26 | ឯកសារស្ដីអំពីសកម្មភាពដំណើរទស្សនកិច្ចរបស់គណៈប្រតិភូគុយបា | P | 00679782 - 00679802 | 00168465 - 00168470 | 00698444 - 00698450 |
| E3/25 | D243/2.1.9 | ទស្សនាវដ្ដីទង់បដិវត្តន៍ លេខពិសេស ធ្នូ–មករា ១៩៧៦.៧៧ | P | 00063039 - 00063040 | 00491406 | |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី ចូលរួមដំណើរការសវនាការពីបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ ដោយបង្គាប់ឲ្យមេធាវីផ្ដល់លិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន និង នួន ជា មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ១៣:៣០។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងរកកន្លែងសម្រាកជូនដល់សាក្សី នៅអំឡុងពេលសម្រាកថ្ងៃត្រង់ និងពេលរសៀល ត្រូវនាំមកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ១៣:៣០ និងម៉ោង ១៥។
- អង្គជំនុំជម្រះបង្គាប់ឲ្យគ្រូពេទ្យប្រចាំការពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា និងរាយការណ៍ភ្លាមអំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា ខៀវ សំផន និងសាក្សី កាំង ហ្កេកអ៊ាវ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ និងសាក្សីត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ២១ ខែ មីនា ឆ្នាំ ២០១២ វេលាម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ដាវ អានសាន់** Roger PHILLIPS